# លោកជំទាវ ជូ ប៊ុនអេង អញ្ជើញចូលរួមជាគណៈអធិបតី បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប រយៈពេលបីថ្ងៃ នៅក្រសួងមហាផ្ទៃ




(ភ្នំពេញ)កាលពីថ្ងៃទី១៣-១៦ ខែកញ្ញា ឆ្នាំ២០១៦ នៅទីស្តីការក្រសួងមហាផ្ទៃ មានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប ដែលរៀបចំដោយ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**។ វគ្គបណ្តុះបណ្តាលគ្រូបង្គោលនេះ គឺធ្វើឡើងក្នុងគោលបំណងផ្តល់ចំណេះដឹង និង ជំនាញដល់ពួកគាត់បានទៅធ្វើការបណ្តុះបណ្តាលបន្តទៀត ដល់ប្រតិបត្តិករទាំងឡាយបានយល់ដឹងកាន់តែច្បាស់អំពីនីតិវិធី និងបែបបទ នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ពីកន្លែងមួយទៅកន្លែងមួយរហូតដល់កន្លែងផ្តល់សេវាណាមួយដែលសមស្របសម្រាប់ពួកគាត់។

វគ្គបណ្តុះបណ្តាលនេះ មានសមាសភាពចូលរួមចំនួន ៣៥រូប ស្រីចំនួន ០៨រូប ដែលក្នុងនោះគ្រូឧទ្ទេសមានចំនួន ០៨រូប ស្រីចំនួន ០២រូប និងសិក្ខាកាមចូលរួមមានចំនួន ២៧រូប មកពីក្រសួងមហាផ្ទៃ, ក្រសួងកិច្ចការនារី, ក្រសួងយុត្តិធម៌, ក្រសួងការពារជាតិ, ក្រសួងសុខាភិបាល, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសង្គមកិច្ច, អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកដ្ឋានអន្តោប្រវេសន៍ កងរាជអាវុធហត្ថលើផ្ទៃប្រទេស, ស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា អង្គការ IOM WINROCK UN-ACT Cambodia ACTs និង APLE ។




នៅថ្ងៃបញ្ចប់ នៃវគ្គបណ្តុះបណ្តាលនេះ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានផ្តល់នូវអនុសាសន៍ និង វិធីសាស្ត្របង្រៀនមួយចំនួនសម្រាប់កែលម្អឲ្យប្រសើរឡើង ដើម្បីយកទៅអនុវត្តនៅវគ្គបណ្តុះបណ្តាលក្រោយៗទៀត ដូចជា៖

-សិក្ខាកាមត្រូវបន្តការបណ្តុះបណ្តាលបន្ថែមទៀតដើម្បីឲ្យកាន់តែច្បាស់លាស់ និងមានគរុកោសល្យខ្ពស់។

-ត្រូវធ្វើយ៉ាងណាឲ្យប្រតិបត្តិករមានការយល់ដឹងរួមមួយអំពីការកំណត់អត្តសញ្ញាណជនរងគ្រោះ កុំឲ្យមានការកំណត់ខុសគ្នា។

-មេរៀននីមួយៗត្រូវមានបញ្ជាក់អំពីគោលដៅ និងគោលបំណងច្បាស់លាស់។

**លោកជំទាវ** មានប្រសាសន៍ថ្លែងអំណរគុណដល់គ្រូឧទ្ទេស និងសិក្ខាកាមជាគ្រូបង្គោលទាំងអស់ដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះទាំងអស់ ត្រូវមានការអត់ធ្មត់បន្តការសិក្សា ដើម្បីឲ្យគ្រូបង្គោលយើងកាន់តែមានទេពកោសល្យល្អប្រសើរថែមទៀត។